# មន្ត្រីបច្ចេកទេសកសិកម្ម

តើអ្នកមានចំណាប់អារម្មណ៍ធ្វើការដើម្បីគាំទ្រ និងលើកស្ទួយដល់សេដ្ឋកិច្ចយុវវ័យបាត់បង់ឱកាស ក្រុមគ្រួសារ និងសហគមន៍របស់គេដែរឬទេ? តើអ្នកចាប់អារម្មណ៍ធ្វើការជាមួយក្រុមការងារ ដែលផ្តល់ការបណ្តុះបណ្តាលជំនាញចិញ្ចឹមសត្វ និងធ្វើកសិសកម្មដែរឬទេ? បើចាប់អារម្មណ៍ អ្នកអាច មកចូលរួមជាមួយយើងបាន!

អ្នកនឹងចូលរួមជាមួយក្រុមការងាររបស់អង្គការមិត្តសំឡាញ់ ដែលមានអ្នកជំនាញជិត ២៥០នាក់ ធ្វើការជាមួយគ្នាដើម្បីផ្តល់នូវសេវាសង្គមជាច្រើនទៅដល់កុមារ និងយុវវ័យបាត់បង់ឱកាស ក្រុមគ្រួសារ និងសហគមន៍របស់គេ។ យើងបានបង្កើតនូវវិធីសាស្រ្តរួមគ្នាមួយចំនួន ដើម្បីគាំទ្រកុមារ ត្រឡប់ទៅរស់នៅជាមួយក្រុមគ្រួសារ និងបន្តការសិក្សារបស់ពួកគេវិញ ផ្តល់ការបណ្តុះបណ្តាលជំនាញ ឬការងារ ទៅដល់យុវវ័យ រួមទាំងការគាំទ្រក្រុមគ្រួសារ និងសហគមន៍ ក្នុងការជួយថៃទាំកូនរបស់ពួកគេ។ យើងបានផ្តល់ការបណ្តុះបណ្តាលដល់យុវវ័យលើជំនាញជាច្រើនដូចជា ចុងភៅ សម្អាងកាយ កាត់សក់ ជាងផ្សា អគ្គីសនី កាត់ដេរ ម៉ូតូ និង ការបណ្តុះបណ្តាលដើម្បីបង្កើតចំណូលដល់អាណាព្យាបាល។

បច្ចុប្បន្ន យើងកំពុងត្រូវការជ្រើសរើសអ្នកមានសមត្ថភាព សម្រាប់មុខតំណែង **មន្រ្តីបច្ចេកទេសកសិកម្ម** ប្រចាំនៅខេត្តកំពង់ឆ្នាំង។

## តើអ្នកនឹងត្រូវធ្វើអ្វី?

ក្នុងតួនាទីជា មន្ត្រីបច្ចេកទេសកសិកម្ម អ្នកត្រូវបានរំពឹងថា នឹងជួយឲសេដ្ឋកិច្ចរបស់យុវវ័យបាត់បង់ឱកាស និងគ្រួសាររបស់ពួកគេ ប្រសើឡើង តាមរយៈការផ្តល់ការបណ្តុះបណ្តាលជំនាញកសិកម្ម និងចិញ្ចឹមសត្វ ដែលអាចឲគាត់រកការងារធ្វើ ឬបង្កើតមុខរបស់ដោយខ្លួនឯងបាន។

## អ្នកនឹងទទួលខុសត្រូវការងារសំខាន់ៗដូចខាងក្រោមៈ

- រៀបចំ និងបង្កើតកសិដ្ឋានគំរូ ដើម្បីផ្តល់ការបណ្តុះបណ្តាល
- ធ្វើការវាយតម្លៃ និងជ្រើសរើសយុវវ័យ និងគ្រួសារ ដើម្បីទទួលការបណ្តុះបណ្តាល
- បណ្តុះបណ្តាលជំនាញ និងបច្ចេកទេសដាំដំណាំ និងការចិញ្ចឹមសត្វ
- រៀបចំវត្ថុធាតុដើម មេរៀន និងផែនការសកម្មភាពបង្រៀន
- តាមដាន និងវាយតម្លៃការសិក្សា និងផ្តល់ការគាំទ្រនានា
- រៀបចំផែនការសកម្មភាព ផែនការថវិការ និងរបាយការណ៍លទ្ធផលការងារតាមការតម្រូវរបស់គម្រោង

## អ្នកត្រូវមានលក្ខណៈសម្បត្តដូចខាងក្រោមៈ

- អ្នកមានសញ្ញាបត្រផ្នែកកសិកម្ម ឬសញ្ញាបត្រដែលមានតម្លៃស្មើ

- អ្នកមានបទពិសោធន៍ពាក់ព័ន្ធ ០១ ទៅ០២ ឆ្នាំជាមួយ អង្គការ ឬស្ថាប័ននានា
- អ្នកជាបុគ្គលឯករាជ្យ អាចគ្រប់គ្រងការងាររបស់ខ្លួនបានយ៉ាងល្អប្រសើរ និងធ្វើការងារជាមួយក្រុមប្រកដោយប្រសិទ្ធិភាព
- អ្នកចេះប្រើប្រាស់កម្មវិធីកុំព្យូទ័រមួយចំនួនដូចជា Word Excel internet & Email
- អ្នកអាចសរសេរ និងអានភាសាអង់គ្លេសបានមធ្យម

## ទីតាំងការងារៈ កំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង

បេក្ខជនទាំងពីរភេទដែលមានចំណាប់អារម្មណ៍ សូមផ្ញើរនូវប្រវត្តិរូបសង្ខេប (CV និង Cover Letter) មកទីស្នាក់ការអង្គការមិត្តសំឡាញ់ អាសយដ្ឋានផ្ទះលេខ២១៥ ផ្លូវលេខ១៣ ខាងជើងសារៈមន្ទីរជាតិ ឬ E-mail: hr@mithsamlanh.org ។ សូមបញ្ជាក់ពីតួនាទីដែលដាក់ដែលពាក្យៈ **មន្ត្រីបច្ចេកទេសកសិកម្ម** និង ប្រាក់បៀរវត្សរ៍ពឹងទុក។ ព័ត៌មានបន្ថែមអាចទំនាក់ទំនងបានតាមរយៈទូរស័ព្ទ ០២៣ ២២០ ៥៩៦/ ០១៦ ៩២៣ ១៥៩/ ០១២ ៩៧៦ ៨៨៩

អង្គការមិត្តសំឡាញ់ ផ្តល់នូវភាពយុត្តិធម៌ដល់អ្នកដាក់ពាក្យទាំងអស់។ បេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងត្រូវទំនាក់ទំនងដើម្បីធ្វើការសម្ភាសន៍។ ស្ត្រីត្រូវបានលើកទឹកចិត្ត ។

**អង្គការមិត្តសំឡាញ់គោរពតាមគោលការណ៍ការពារកុមារ។**
**ទទួលពាក្យចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២១។**